# គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា
## សេចក្តីសង្ខេបស្តីពីផែនការផ្សារភ្ជាប់ជាមួយភាគីពាក់ព័ន្ធ

ឯកសារផែនការផ្សារភ្ជាប់ជាមួយភាគីពាក់ព័ន្ធនេះ ត្រូវបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ **«គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា»** ដោយការិយាល័យសង្គម និងបរិស្ថាន របស់ក្រសួងទាំងពីរ ដោយមានការគាំទ្រពីទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិ។ ផែនការនេះ ប្រើប្រាស់ចំពោះគម្រោងវិនិយោគក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក និងត្រូវបានចាត់ទុកជាឯកសាររស់ដោយអាចធ្វើបច្ចុប្បន្នភាពស្របតាមស្ថានភាពនិងសកម្មភាពជាក់ស្តែង។

### អំពីគម្រោង

គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា នឹងធ្វើការកែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ សំដៅធ្វើឲ្យផ្លូវមានភាពធន់ ឬបន្សាំនឹងការបម្រែបម្រួលអាកាសធាតុ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ។ ផ្លូវដែលត្រូវកែលម្អ រួមចំណែកលើកកម្ពស់ភាពធន់ និងសុវត្ថិភាពនានានៃបណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដោយត្រូវធ្វើការក្រាលកៅស៊ូ/បេតុង និងកែលម្អសំណង់សិល្បការ្យនានាតាមស្តង់ដា និងបទដ្ឋានបច្ចេកទេសសមស្របដើម្បីធានាភាពធន់ និងប្រើប្រាស់បានយូរអង្វែង ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក។

សមាសភាពទី១៖ ក្រសួងសាធារណការ នឹងដឹកជញ្ជូន ធ្វើការស្តារឡើងវិញផ្លូវប្រវែង ១៣០ គីឡូម៉ែត្រ ក្រោមហិរញ្ញប្បទាន របស់ធនាគារពិភពលោក សម្រាប់ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ។
សមាសភាពទី២៖ ក្រសួងអភិវឌ្ឍន៍ជនបទ ធ្វើការស្តារឡើងវិញ ផ្លូវជនបទប្រវែង ២៥០ គីឡូម៉ែត្រ ក្រោមហិរញ្ញប្បទាន របស់ធនាគារពិភពលោក សម្រាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ។

### ផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ

ផែនការនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីធានាថាសហគមន៍ និងអ្នកពាក់ព័ន្ធជាមួយគម្រោងត្រូវបានជូនដំណឹង និងចូលរួមគ្រប់ដំណាក់កាលនៃការរៀបចំ និងអនុវត្តគម្រោង ដោយត្រូវពិគ្រោះយោបល់ដើម្បីទទួលយកជាតុចូលប្រកបដោយបរិយាប័ន្ន និងត្រូវរៀបចំតួនាទី ភារកិច្ចរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះក្នុងដំណើការនៃការពិគ្រោះយោបល់។ គម្រោងផ្តោតសំខាន់លើយន្តការកាត់បន្ថយហានិភ័យ ដើម្បីធានាថាអ្នកទទួលរងផលប៉ះពាល់ត្រូវបានចូលរួមក្នុងកម្មវិធីអប់រំសុវត្ថិភាពចរាចរ និងវិធានចាំបាច់នានា ដោយទទួលយកនូវរាល់មតិយោបល់ សំដៅបន្តការត្រួតពិនិត្យដំណើការអនុវត្តគម្រោង។

សេចក្តីសង្ខេបអំពីអ្នកពាក់ព័ន្ធដែលត្រូវទទួលរងផលប៉ះពាល់ គឺផ្តោតលើអ្នកប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលលើការកែលម្អផ្លូវ ម្យ៉ាងទៀតផែនការនេះពិពណ៌នាពីប្រភេទអ្នកពាក់ព័ន្ធ និងបញ្ជាក់ពី

វិធីសាស្ត្រជាក់លាក់ និងពេលវេលាត្រឹមត្រូវដើម្បីផ្សារភ្ជាប់ទំនាក់ទំនងគ្នាតាមដំណាក់កាលផ្សេងៗគ្នា នៅពេលអនុវត្តគម្រោង។ ការពិគ្រោះយោបល់ត្រូវបានកត់ត្រានូវមតិយោបល់របស់ភាគីពាក់ព័ន្ធ និង បញ្ជាក់ពីប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ ព្រមទាំងយន្តការក្នុងការដោះស្រាយពាក្យបណ្តឹង។